ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខៈ ១៤៦ MIH / ២០១៧

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យអនុវត្តគោលការណ៍រួមនៃការកំណត់ថ្លៃលក់ទឹកស្អាត

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ១៥៧ អនក្រ.បក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានទឹកស្អាតនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញប្រកាសលេខ ៤៦១ MIH/2014 ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៤ ស្តីពីនីតិវិធីសម្រាប់ការចេញ កែសម្រួល បន្ត ព្យួរ និងដកហូតប្រកាសអនុញ្ញាតឲ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត
- បានឃើញប្រកាសលេខ ០៦៩ MIH/2016 ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ ស្តីពីនីតិវិធីនៃការកំណត់ថ្លៃលក់ទឹកដែល អ្នកផ្គត់ផ្គង់សេវាទឹកស្អាត មានសិទ្ធិយកពីអ្នកទទួលសេវាទឹកស្អាត
- យោងតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវអគាររដ្ឋបាលខេត្ត និងហេដ្ឋារចនាសម្ព័ន្ធនៃទីរួមខេត្តត្បូងឃ្មុំ នាថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧
- យោងតាមសំណូមពរការងារចាំបាច់

## ស ម្រេ ច

**ប្រការ១._**

ត្រូវបានដាក់ឱ្យអនុវត្តគោលការណ៍រួមនៃការកំណត់ថ្លៃលក់ទឹកស្អាត ដែលផលិត និងផ្គត់ផ្គង់ដោយអ្នកផ្គត់ផ្គង់សេវាទឹកស្អាត (ទាំងផ្នែកសាធារណៈ និងផ្នែកឯកជន) ក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ២១១ ៨៩៤
អ៊ីមែល: mih.smcabinet@gmail.com

**ប្រការ២._**

ថ្លៃលក់ទឹកស្អាត ត្រូវបានបែងចែកទៅតាមកម្រិតអ្នកប្រើប្រាស់ ដោយកំណត់ដូចខាងក្រោម ៖

- កម្រិតប្រើប្រាស់ចាប់ពី ០ម៣ ដល់ ៣ម៣ ៖ ថ្លៃលក់ទឹកស្អាត ត្រូវបានកំណត់ស្មើនឹងថ្លៃដើមផលិត ដោយផ្អែកលើការគិតគូរអំពីជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលមានចំណូលទាប
- កម្រិតប្រើប្រាស់ចាប់ពី ៤ម៣ ឡើងទៅ ៖ ថ្លៃលក់ទឹកស្អាត ត្រូវកំណត់ទៅតាមកម្រិតថ្លៃមួយដោយឡែក ផ្អែកតាមភូមិសាស្ត្រជាក់ស្តែងនីមួយៗ ដោយមានការឯកភាពពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឈរលើស្មារតីការពារផលប្រយោជន៍ប្រជាពលរដ្ឋដែលជាអ្នកប្រើប្រាស់ និងអ្នកផ្គត់ផ្គង់ទឹកស្អាត។

**ប្រការ៣._**

អ្នកផ្តល់សេវាទឹកស្អាតទាំងអស់ ត្រូវពិនិត្យ កែសម្រួលប្រព័ន្ធវិក្កយបត្រ ទៅតាមប្រភេទថ្លៃលក់ទឹកស្អាត តាមកម្រិតនីមួយៗ ដោយអនុលោមតាមប្រការ២ នៃប្រកាសនេះ។

**ប្រការ៤._**

ការកំណត់ថ្លៃលក់ទឹកស្អាតតាមគោលការណ៍រួមនេះ ចាប់អនុវត្តពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៧ តទៅ។

**ប្រការ៥._**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦._**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានវិទ្យាស្ថាន ប្រធានមជ្ឈមណ្ឌល មន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត គ្រប់អង្គភាពពាក់ព័ន្ធ និងអ្នកផ្តល់សេវាទឹកស្អាតទាំងអស់ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០១៧

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលារាជធានី ខេត្ត
- សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា
  *«ដើម្បីជូនជ្រាប»*
- ដូចប្រការ៦
  *«ដើម្បីអនុវត្ត»*
- ឯកសារ-កាលប្បវត្តិ



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣២១១ ៨៩៤
អ៊ីមែល: mih.smcabinet@gmail.com